**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តពោធិ៍សាត់**

**វិទ្យាល័យព្រះម្លូរ**

<u>ប្រធានបទ</u>

# " តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍រឿងទុំទាវ "


គ្រូអក្សរសាស្ត្រខ្មែរ **ពៅ វណ្ណៈ** បង្រៀននៅវិទ្យាល័យព្រះម្លូរ

ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ១០ កញ្ញា ១៩៨៧

លេខទូរស័ព្ទ ០៨៩ ៧៦៥ ៥៦៨ ០៩៧ ២៦២ ៣៨៣៨


ថ្ងៃចន្ទ៥រោច ខែមាឃ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ២៥៦១

វិទ្យាល័យព្រះម្លូរ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៨

# សេចក្ដីផ្ដើម

គ្រប់ជាតិសាសន៍ទាំងអស់តែងតែមានអត្តសញ្ញាណជាតិរបស់ខ្លួន។ ប្រវត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសកម្ពុជាជាប្រទេសមួយដែលមានវប្បធម៌អរិយធម៌ថ្កុំថ្កើងរុងរឿងត្រចះត្រចង់ មានវប្បធម៌ដ៏ចំណាស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ នៅក្នុងវប្បធម៌ដ៏មានវ័យចំណាស់នេះ ខ្មែរយើងមានការរីកចម្រើនយ៉ាងខ្លាំងក្នុងវិស័យអក្សរសិល្ប៍។ នេះជាការពិតឥតក្លែងបន្លំ ព្រោះវាមិនអាចជាការនិយាយបំផ្លើស ឬអួតអាងដោយគ្មានតឹកតាងបញ្ជាក់ និងសំអាងនោះឡើយ។ គ្រប់អត្ថបទអក្សរសិល្ប៍សុទ្ធតែបានផ្ទុកនូវចំណេះដឹង ស្ដីពីបាតុភូតជាក់ស្ដែងនៃជីវិតរស់ៈ ហើយវាក៏បានឆ្លុះបញ្ចាំងនូវបាតុភូតទាំងឡាយដែលមាននៅក្នុងសង្គម ពិសេសទៅតាមក្រិត្យក្រមនៃការរីកចម្រើនរបស់សង្គម។ អក្សរសិល្ប៍បានផ្ដល់ឱ្យអ្នកអាន អ្នកសិក្សានូវចំណេះដឹងស្ដីពីជីវិត គឺបញ្ហាមនុស្សដែលទាក់ទងនឹងទំនៀមទម្លាប់ប្រពៃណី ភូមិសាស្ត្រ ប្រវត្តិសាស្ត្រជាដើម។ តាំងពីអតីតកាលក៏ដូចបច្ចុប្បន្នកាល ស្នាដៃអក្សរសិល្ប៍ត្រូវបានចាត់ទុកជា "សៀវភៅសិក្សាស្ដីពីជីវិត"។ អ្នកនិពន្ធធំៗទាំងឡាយបានចាត់ទុកជា "វិស្វករនៃព្រលឹង" នេះអាស្រ័យមកពីស្នាដៃអក្សរសិល្ប៍និងអ្នកនិពន្ធធំៗបានដើរតួនាទីសំខាន់ក្នុងការបណ្ដុះបណ្ដាលនិងការអប់រំមនោគមវិជ្ជា មនោសញ្ចេតនារបស់មនុស្ស។

ទន្ទឹមនឹងនេះ ស្នាដៃអក្សរសិល្ប៍នៃរឿងទុំទាវ (របស់អ្នកនិពន្ធភិក្ខុសោម) ក៏បានដើរតួនាទីដ៏សំខាន់ក្នុងការស្ដែងឱ្យឃើញពីផ្នត់គំនិត និងមានតម្លៃសំខាន់បំផុតសម្រាប់ជាតិខ្មែរ។ រឿងទុំទាវជារឿងមួយដែលប្រជាជនខ្មែរយើងនិយមរាប់អានយ៉ាងខ្លាំង និងត្រូវបានចាត់ចូលទៅក្នុងរឿងដែលមានតម្លៃជាសកលគ្រប់សម័យកាលថែមទៀតផង។

តើតម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍រឿងទុំទាវ ផ្អែកលើកត្តាអ្វីខ្លះ?

កត្តាសំខាន់ៗដែលអាចឱ្យគេកំណត់តម្លៃ ជាសកលរបស់ស្នាដៃអក្សរសិល្ប៍រឿងទុំទាវមានដូចតទៅៈ

**១.<u>កត្តាទី១</u> : រឿងទុំទាវជាស្នាដៃអក្សរសិល្ប៍បង្ហាញពីលក្ខណៈស៊ីជម្រៅក្នុងអក្សរសិល្ប៍បែបខេមរនិយម និងឆ្លុះបញ្ចាំងឱ្យឃើញពីភាពគ្រប់ជ្រុងជ្រោយនៃតថភាពសង្គមរបស់ជាតិមួយ**

ដំណើររឿង បានបង្ហាញឱ្យឃើញពីស្ថានភាព ជីវភាពរស់នៅរបស់មនុស្សខ្មែរគ្រប់រសជាតិរួមមាន បញ្ហានយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌យ៉ាងជាក់ច្បាស់ដល់អ្នកសិក្សាគ្រប់រូប គ្រប់ជំនាន់បានមើលឃើញ និងដកស្រង់ជាបទពិសោធបាន។

**ក. ផ្នែកនយោបាយ និងការគ្រប់គ្រង**

+ **អំណាចស្ដេចផែនដី** : នៅក្នុងរឿងទុំទាវស្ដេចផែនដីមានអំណាចគ្រប់គ្រងលើប្រជារាស្ត្រ និងពួកស្ដេចត្រាញ់។ តាមការបង្ហាញរបស់អ្នកនិពន្ធ ការដែលស្ដេចរាមាខឹងនឹងអរជូនខ្លាំងបំផុតនោះ គឺមិនមែនដោយសារតែមរណភាពរបស់ទុំទាវទេ គឺមកពីអរជូនហ៊ានប្រឆាំងនឹងព្រះរាជបញ្ជារបស់ព្រះអង្គតែប៉ុណ្ណោះ។

ឧទាហរណ៍ : " វាហ៊ានទទឹងនឹងអញធ្មោះ ទោសកាប់ស្មោស្រុះរាស់ជីកបង់

ជីកបុកក្នុងដីក្ស័យរូបអង្គ កុំសង្ស័យសោះអាអរជូន " ។

+ **អំណាចស្ដេចត្រាញ់** : ស្ដេចត្រាញ់គ្រប់គ្រង និងមានអំណាចអាចកាប់សម្លាប់មនុស្សដោយមិនបាច់វិនិច្ឆ័យ។

ឧទាហរណ៍ : " ឧកញ៉ាអរជូនមាំមួនពេក ធម្មតាក្រោមមេឃទាបជាងភ្នំ

មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី " ។

+ **អំណាចមេគ្រួសារ** : ក្នុងគ្រួសារកូនគ្មានសិទ្ធិអ្វីទាំងអស់ សូម្បីតែសិទ្ធិជ្រើសរើសគូស្រករក៏ត្រូវគេដកហូតយកដែរ។

ឧទាហរណ៍:"មិនដែលសោះឡើយទាវអើយនំ ច្រឡើសបើសធំម្ដេចជាងនាឡិ

កូនគោកាចកៀចដោយព្រៃវាល រោលរាលឈឺខ្លួនជូនដល់ស្លាប់"។

**ខ.ផ្នែកសេដ្ឋកិច្ច**

**+ កសិកម្ម** : ស្ថានភាពទឹកដីប្រទេសខ្មែរ បង្កលក្ខណៈប្រសើរដល់វិស័យកសិកម្មជាពិសេសលើដំណាំស្រូវ ពោត សណ្ដែក ថ្នាំ ដូង ស្លា... ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការទ្រ

ទ្រង់សេដ្ឋកិច្ចជាតិតាំងពីអតីតកាលរហូតដល់បច្ចុប្បន្នកាល។

**+ពាណិជ្ជកម្ម** : មានលក់ទំនិញមានចាយលុយកាក់មានទីផ្សារ និងមានការដោះដូរគ្នាទៅវិញទៅមក។

ឧទាហរណ៍ : "ដល់ក្រុងភ្នំពេញដែនដីរាប    រសៀលទន់ទាបព្រះសុរិយា

ឡើងមើលទំនិញគ្រប់តាមផ្សារ    គ្រៀបគ្រាចិនខ្មែរហៃគឹកកង"។

**+ឧស្សាហកម្ម** : ប្រជាជនផលិតរបស់របរប្រើប្រាស់ដូចជា ព្រៃ សំពត់សូត្រ កន្សែងទឹកអប់ សាប៊ូ គោក...។

ឧទាហរណ៍ : "សឹងប្រែសូត្រសុទ្ធសាច់ល្អស្អាត    លាំងកៃម៉ូតម៉ាតពណ៌លឿងខ្ចី

សប្បុរស្រៀបស្រស់ឆ្លុះរស្មី    នៅថ្មីភ្លឺទែងកន្សែងស"។

**+គមនាគមន៍** : គេឃើញមានជើងទឹកប្រើទូក ឯផ្លូវគោកប្រើរទេះគោ ឬដោយថ្មើរជើងជាដើម។

ឧទាហរណ៍ : "នេនរៀបបម្រុងការុងបាយ    បង្ការទៅឆ្ងាយផ្លូវគ្រាច់ចរ

ប្រឹងអូសរទេះមកបញ្ឈរ    ដឹកគោទឹមបរចរចេញទៅ"។

**+បរិស្ថាន** :បង្ហាញឱ្យឃើញពីភាពសម្បូរបែបនៃធនធានធម្មជាតិ ដូចជាព្រៃឈើ សត្វព្រៃ បក្សាបក្សី និងមច្ឆជាតិគ្រប់ប្រភេទ។

ឧទាហរណ៍(ព្រៃឈើ) :

"មើលមានជ្រៃជ្រែសង្កែថ្នាន់    ក្រៀលត្រល់ក្រវ៉ាន់គុយស្រគុំ

ស្រឡីស្រឡៅក្រចៅក្ទម្ព    ទ្រនុំអាអូដ្ឋចង្អូរត្នោត"។

ឧទាហរណ៍(សត្វព្រៃ) :

"បងស្តាប់សូរសព្ទរៃកណ្តឹង    មាន់ព្រៃប្រប្រឹងរងាវឆ្លើយ

បងនឹករឭកទាវទៀតហើយ    ទាវអើយសមសួនន្ទួនកំព្រា"។

ឧទាហរណ៍(មច្ឆជាតិ) :

"រ័ស់ឆ្តោកាហោរាជរាហ៊ូ        ព្រួលប្រាទីពោព្រុយកន្លង់

ដំរីក្អិតក្អីឫស្សីច-             ង្វាត្លៀងរហង់រហ័សហៃល"។

**គ.ផ្នែកសង្គមកិច្ច**

វិស័យនេះមិនទាន់រីកចម្រើននៅឡើយទេ ព្រោះរាស្ត្ររស់នៅតាមសមត្ថភាពរៀងៗខ្លួន គ្មានមន្ទីរពេទ្យ គ្មានអង្គការសិទ្ធិមនុស្ស។ ការបន់ស្រន់ជាវិធីមួយស្វែងរកសេចក្ដីសុខរបស់មនុស្សសម័យនោះ។

**ឃ.ផ្នែកវប្បធម៌**

**+ជំនឿ** : ប្រជាជនមានជំនឿលើកម្មផល ជឿលើការទស្សន៍ទាយ និងជឿលើមន្តអាគមគាថា។

ឧទាហរណ៍ : "ពុំគួរបណ្ដោយឱ្យសឹកទៅ  វាយលេខឃើញត្រូវពានលើងាប់

ទំនាយទាយទុំថាអភ័ព្វ    ឃាត់ជាប់ទម្រាំដាច់ឆ្នាំហ្នឹង"។

**+សាសនា** : ប្រជាជនគោរពបូជាព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។ ដូចជាម្ដាយទាវទៅវត្តរាល់ថ្ងៃសីល ហើយទុំបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនា។

**+ទំនៀមទម្លាប់** : កូនប្រុសត្រូវបួសរៀននៅក្នុងវត្តអារាម ចំណែកកូនស្រីពេញវ័យត្រូវចូលម្លប់។

**+ប្រពៃណី** : មានការចែចូវស្ដីដណ្ដឹង និងការរៀបអាពាហ៍ពិពាហ៍។

**+សិល្បៈ** : ប្រជាជនចូលចិត្តស្ដាប់តន្ត្រីគ្រប់ស្រទាប់វណ្ណៈរហូតដល់ព្រះមហាក្សត្រ។ ក្រៅពីនេះ នៅមានប្រគុំភ្លេងខ្មែរក្នុងពិធីមង្គលការនិងមានការស្មូតអមកំដរដោយប៉ុធ្វើជាបែបបទផ្សេងៗ។

**+ការសិក្សាអប់រំ** : វត្តអារាមជាឃ្លាំងគម្ពីរដីការផ្សេងៗ។ ដូច្នេះការសិក្សាមាននៅតាមវត្តអារាមដែលមានព្រះសង្ឃជាគ្រូអាចារ្យ។ ចំណែកកូនស្រីត្រូវរៀនច្បាប់ផ្សេងៗតាមរយៈការចូលម្លប់។

**២.កត្តាទី២ : រឿងទុំទាវជាស្នាដៃអក្សរសិល្ប៍បានបង្កប់ពីលក្ខណៈជាតិដ៏ជ្រាលជ្រៅ**

រឿងទុំទាវ ជាអក្សរសិល្ប៍មានលក្ខណៈជាតិ បានបង្ហាញនូវលក្ខណៈពិសេសរបស់ជាតិដែលខុសប្លែកពីបរទេស។ លក្ខណៈជាតិដែលស្តែងចេញតាមរយៈរឿងទុំទាវគឺ៖

**+ការបង្ហាញតួអង្គ** : តួអង្គក្នុងរឿងទុំទាវសុទ្ធតែបានបង្កប់នូវលក្ខណៈជាតិមួយពិតប្រាកដ ជាក់ស្តែងដូចជា :

**ទុំ** : ពេញវ័យត្រូវទៅបួសរៀននៅវត្ត ដើម្បីរៀនធម៌ រៀនអក្សរ និងរៀនវិជ្ជាជីវៈផ្សេងៗដែលមានព្រះសង្ឃជាគ្រូ។

**នាងទាវ** : ពេញវ័យត្រូវចូលម្លប់តាមទំនៀមទម្លាប់របស់ខ្មែរនាសម័យនោះដើម្បីរៀនវិជ្ជាមេផ្ទះ និងការរៀបចំចិត្តគំនិតដើម្បីគ្រប់គ្រងគ្រួសារ។

**ម្តាយទាវ** : តំណាងឱ្យចិត្តគំនិតម្តាយខ្មែរទាំងឡាយដែលចង់ឱ្យកូនខ្ពស់មុខមាត់តាមរយៈទ្រព្យសម្បត្តិ បុណ្យសក្តិ ក្នុងការទុកដាក់កូនចៅឱ្យមានគូស្រករ។

**អរជូន** : តំណាងឱ្យមន្ត្រីខ្មែរដែលមានអំណាចផ្តាច់ការ។

**ព្រះបាទរាមា** : តំណាងឱ្យរបបសង្គមខ្មែរដែលគោរពរបបរាជានិយម។

**+ប្រពៃណីទំនៀមទម្លាប់**:ការស្តីដណ្តឹងគឺបុរសដណ្តឹងស្ត្រីរៀបការនៅផ្ទះខាងស្រី។

នេះជាទម្លាប់របស់ខ្មែរមួយដែលអនុវត្តតាមរបបមាតាធិបតេយ្យក្នុងការឱ្យតម្លៃស្ត្រីជាធំ។ មួយទៀត ការនិមន្តព្រះសង្ឃមកសូត្រមន្តនៅតាមគេហដ្ឋានក៏ជាទម្លាប់របស់ខ្មែរ តាំងពីបុរាណរហូតមកដល់បច្ចុប្បន្នដែរ។ ឯចំពោះ តន្ត្រីចម្រៀងក៏ជាលក្ខណៈប្រពៃណីខ្មែរ ដែលតាំងពីប្រជាជនរហូតដល់ព្រះរាជាសុទ្ធតែនិយមចូលចិត្តសិល្បៈដូចៗគ្នា។

**+ផ្ទត់គំនិត** : តាមដំណើររឿង យើងឃើញថាគ្រូរបស់ទុំ មុននឹងឱ្យទុំ ពេជ្រសឹក លោកគ្រូបានគន់គូរវាយជើងលេខសិន មានន័យថាប្រជាជនមានជំនឿលើការទស្សន៍ទាយរបស់ហោរា។ ពេលទុំ ឃើញនាងទាវ ទុំបានសែកមន្តលិនថោងសារិកាដាក់ឱ្យនាងទាវស្រលាញ់។ ជំនឿលើកម្មផលដោយគោរពព្រះពុទ្ធសាសនា ម្តាយទាវទៅវត្តរៀងរាល់ថ្ងៃសីល។

**+អំពីធម្មជាតិ** : តាមរយៈដំណើររឿង អ្នកនិពន្ធបានរៀបរាប់ពិពណ៌នាយ៉ាងក្បោះក្បាយនូវទិដ្ឋភាពធម្មជាតិដែលទាក់ទងនឹងព្រៃព្រឹក្សា បក្សាបក្សី និងមច្ឆជាតិដែលមាននៅក្នុងប្រទេសយើង។

**+អំពីភូមិសាស្ត្រ** : អ្នកនិពន្ធបានរៀបរាប់ធ្វើឱ្យដំណើររឿងកើតឡើងទាក់ទងនឹងទីតាំងភូមិសាស្ត្រនៃប្រទេសខ្មែរយើង ដូចជាបាភ្នំ ត្បូងឃ្មុំ លង្វែក...ជាដើម។

**+អំពីភាសា** : ក្នុងការនិពន្ធរឿងទុំទាវ ព្រះភិក្ខុសោមបានប្រើភាសាជាតិជាមូលដ្ឋាន សូម្បីតែឈ្មោះតួអង្គ ដូចជាទុំ ទាវ ពេជ្រ នោ...។ ជាងនេះទៅទៀត ដំណើររឿងទាំងមូល អ្នកនិពន្ធបានសរសេរជាកំណាព្យបទពាក្យប្រាំពីរ មានចំណាប់ចួនពីរោះរណ្តំណែងណងឥតខ្ចោះតាមលំនាំខ្មែរសុទ្ធសាធដែលយើងអាចអានក៏បាន ស្មូតក៏បាន ច្រៀងក៏បាន។

**+លក្ខណៈព្រលឹងជាតិ** : ព្រលឹងជាតិតាមរយៈរឿងទុំទាវ គឺភក្តីភាពរបស់តួអង្គទុំទាវនេះឯងដែលតំណាងឱ្យចរិតរបស់ខ្មែរយើង។

**៣.<u>កត្តាទី៣</u> : វិសាលភាពនៃវត្តមានរបស់រឿងទុំទាវ**

តាមការសង្កេតជាក់ស្តែង យើងឃើញថារឿងទុំទាវគឺបានបង្ហាញខ្លួន និងទទួលបានការឱ្យតម្លៃស្មើរគ្រប់សម័យកាល។ រឿងទុំទាវត្រូវបានបុព្វអ្នកនិពន្ធខ្មែរគ្រប់ជំនាន់ឱ្យតម្លៃ និងតាក់តែងជាបែបបទផ្សេងៗពីគ្នា ឱ្យកូនខ្មែរជំនាន់ក្រោយសិក្សាស្វែងយល់។

អត្ថបទដែលត្រូវបាននិពន្ធជាបន្តបន្ទាប់ទាំងនោះរួមមានៈ

**ក.អត្ថបទទី១** : សរសេរលើស្លឹករឹត ជាបទពាក្យ៧យ៉ាងចំណាស់ តែងក្នុងឆ្នាំ

១៨៥៧។ ដោយយល់ទៅតាមទេពកោសល្យខ្ពស់ក្នុងការតែងកំណាព្យ អាចឱ្យគេសន្និដ្ឋានបានថាជាអត្ថបទរបស់កវី សន្ធម៉ុក(១៨៣៩-១៩០៨)។

**ខ.អត្ថបទទី២** :សរសេរលើស្លឹករឹតជាបទកាព្យផ្សេងៗ មានបទកាកគតិ បទព្រហ្មគីតិជាដើម។ ដោយផ្អែកលើជរាភាពនៃសាស្ត្រានេះ ប្រហែលជារៀបរៀងឡើងមុនរជ្ជកាលសម្ដេចនរោត្តមទៅទៀត។

**គ.អត្ថបទទី៣** : ជាស្នាដៃនិពន្ធរបស់ភិក្ខុសោម តែងជាបទពាក្យប្រាំពីរ ក្នុងឆ្នាំ១៩១៥ មាន ១០៥០ល្បះ និងជាស្នាដៃដែលមានកម្រិតខ្ពស់ បើធៀបទៅនឹងស្នាដៃអក្សរសិល្ប៍នានា។

**ឃ.អត្ថបទទី៤** : ជាស្នាដៃរបស់ឧកញ៉ាវិបុលរាជនូកន តែងជាបទពាក្យប្រាំបីក្នុងឆ្នាំ១៩៤២ ហើយបានដូរឈ្មោះថាទាវឯក។

ទន្ទឹមនឹងនេះក្រសួងអប់រំជាតិនៃកម្ពុជា កាលពីសង្គមចាស់ក៏បានឱ្យតម្លៃទៅលើរឿងនេះដែរ ដែលគេចាត់ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៣ និងថ្នាក់ទី១ចាស់ ហើយបច្ចុប្បន្ននេះក្រសួងអប់រំ យុវជន និងកីឡាក៏បានបញ្ចូលរឿងទុំទាវនេះទៅក្នុងកម្មវិធីសិក្សានៅថ្នាក់ចំណោះទូទៅ(ថ្នាក់ទី១០ ១១ ១២)។ មិនត្រឹមតែសម្រាប់អ្នកសិក្សាប៉ុណ្ណោះទេ រឿងទុំទាវត្រូវបាន មជ្ឈដ្ឋានអ្នកសិល្បៈយកទៅសម្ដែងជាល្ខោនយីកេ ជាភាពយន្តជូនទស្សនិកជនជាទីកម្សាន្ត យ៉ាងល្អឥតខ្ចោះថែមទៀតផង។ ជាពិសេសជាងនេះទៅទៀត ស្នាដៃអក្សរសិល្ប៍នៃរឿងទុំទាវនេះក៏ត្រូវបានផ្សព្វផ្សាយជាលក្ខណៈអន្តរជាតិផងដែរ។ ជាក់ស្ដែងរឿងនេះ លោកGeorge Chigas បានបកប្រែ និងវិភាគជាភាសាអង់គ្លេស(TUM TEAV : A Translation and Analysis of a Cambodian Literary Classic) ហើយបោះពុម្ព និងផ្សព្វផ្សាយជាសកល(២០០៥)។ ត្រង់ចំណុចនេះ ចង់បញ្ជាក់ថារឿងទុំទាវត្រូវបានឱ្យតម្លៃជាទូទៅ ទាំងអ្នកអានអ្នកស្ដាប់ អ្នកនិពន្ធ និងអ្នកវិភាគអក្សរសិល្ប៍គ្រប់មជ្ឈដ្ឋាន ទាំងក្របខ័ណ្ឌជាតិនិងអន្តរជាតិ។

៤.<u>កត្តាទី៤</u> : **អ្នកនិពន្ធរឿងទុំទាវមានគំនិតជឿនលឿន**

រឿងទុំទាវ អ្នកនិពន្ធមានគំនិតជឿនលឿនខ្លាំង បើប្រៀបទៅនឹងស្នាដៃនានា។ ពោលគឺប្លែកពីអក្សរសិល្ប៍ដទៃត្រង់៖

**ក.លើកយកបញ្ហាជីវភាពរស់នៅរបស់រាស្ត្រក្នុងសង្គមខ្មែរសម័យលង្វែក**

**+នេនទុំ នេនពេជ្រ** : មានជីវភាពប្លែកពីព្រះសង្ឃសព្វថ្ងៃ។ នេនទុំនិងពេជ្រធ្វើ ជំនួញលក់តោក។ ជាមួយគ្នានេះ តាមរយៈនេនទុំនិងពេជ្រ ឃើញថាព្រះសង្ឃចេះសិល្បៈថែមទៀត គឺចេះស្មូត ផ្លុំប៉ី...។

**+រាស្ត្រអ្នកមាន** : ម្ដាយទាវ គឺតំណាងឱ្យមាតាទាំងឡាយនៅសម័យលង្វែក មានទ្រព្យសម្បត្តិច្រើន រហូតដល់មានបាវព្រាវប្រើលាងជើង ហើយប្រើអំណាចផ្ដាច់ការក្នុងការរៀបចំទុកដាក់កូនចៅ។

**+រាស្ត្រអ្នកក្រ** : រស់នៅខ្លាចគេ ដូចអ្នកស្រុកត្បូងឃ្មុំធ្វើតាមបង្គាប់អរជូន ទោះបី អរជូនដឹកនាំប្រព្រឹត្តខុស ឬមិនបានផ្ដល់ប្រយោជន៍ដល់ពួកគេក៏ដោយ។

**+វណ្ណៈខ្ញុំបម្រើគេ** : មាននាងនោ ជាតំណាងមានចិត្តស្មោះត្រង់និងប្ដូរផ្ដាច់ចំពោះចៅហ្វាយនាយដល់ទីបំផុត។

**+ពួកនាម៉ឺនមន្ត្រី** :មានអរជូន ជាតំណាងមានសកម្មភាពប្រើអំណាចផ្ដាច់ការមកលើរាស្ត្រ។ យកមនុស្សទៅសម្លាប់ ដោយឥតមានជំនុំជម្រះរកខុសត្រូវឡើយ។

**+វណ្ណៈស្ដេច** : មានអំណាចច្រើនដូចជា ការររកស្រីស្នំដែលមានលក្ខណៈប្រព្រឹត្តទៅតាមផ្លូវច្បាប់ព្រោះមានអាមាត្រទាំងឡាយដើររកគ្រប់ច្រកល្ហក ហើយទោះស្រីនោះយល់ព្រមក្ដី មិនយល់ព្រមក្ដី។

**+វណ្ណៈអ្នកងារ** : ធ្វើការឥតកម្រៃ រស់នៅក្រោមការគាបសង្កត់ពីអ្នកដទៃទាំងផ្លូវកាយ ផ្លូវចិត្ត។

**ខ.បង្ហាញឱ្យឃើញពីការទាមទារសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ**

យុវជនស្វែងរកសិទ្ធិសេរីភាពក្នុងការស្វែងរកសុភមង្គល ដោយប្រឆាំងនឹងទស្សនៈចាស់គំរិល "នំមិនធំជាងនាឡិ" ឬ "ពងមាន់កុំជល់នឹងថ្ម"។ តាមរយៈ មរណភាពរបស់ទុំទាវ គឺអ្នកនិពន្ធមានបំណងចង់ពញ្ញាក់ស្មារតីដល់មាតាបិតាទាំងឡាយ ឱ្យគិតពិចារណាឡើងវិញចំពោះការរៀបចំគូស្រករឱ្យបុត្រធីតា។

**៥.<u>កត្តាទី៥</u>: បង្ហាញពីភាពសម្បូរបែបនៃសិល្បវិរូបារម្មណ៍ដែលជាលក្ខណៈលេចធ្លោនៃលក្ខណៈពិសេសរបស់អក្សរសិល្ប៍ខ្មែរ**

លក្ខណៈពិសេសនៃសិល្បរូបារម្មណ៍ក្នុងអក្សរសិល្ប៍រឿងទុំទាវមានដូចតទៅៈ

**ក.ឧបមានរូបារម្មណ៍**

ឧទាហរណ៍ : "ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា ឯអ្នកឧបមាដូចកន្លង់
ហើររកឃើញផ្កាហើរត្រឹបត្រង់ រួចមិនបង្អង់ត្រាច់លីលា"។

**ខ.ឥន្ទ្រិយរូបារម្មណ៍**

**+ចក្ខុរូបារម្មណ៍**

"រួចនេនស្តាប់ជាក់ភ្ញាក់ព្រើតប្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ
យល់ទាវឈរស្ទើរដើររេរា ស្ទុះស្ទាចូលក្នុងស្លុងចេញក្រៅ"។

**+សោតរូបារម្មណ៍**

"សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកំលោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់សព្វភាសា"។

**+ឃានរូបារម្មណ៍**

"ទឹកអប់ត្រឡប់គន្ធរស សាប៊ូជូតដុះជ្រះសន្លាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង ដោយយល់សំណាងសាមណេរនេន"។

**+ជីវ្ហារូបារម្មណ៍**

"គ្រឿងទេសគ្រឿងតែងបន្លែគ្រប់ ទុកមនុស្សប្រសប់ទិញស្រាខ្លាំង

សាច់ក្រកសាបក្រៀមសាច់ចៀនអាំង បបែលទំពាំងក្រសាំងខ្យង"។

**+កាយរូបារម្មណ៍**

"ទុំមានវោហាប្រាជ្ញាផ្សេង មានទាំងសំឡេងរូបខ្ចីល្វក់

ល្អទ្រង់អង្គកាយសាយទឹកមុខ រួចទុកនេនពេជ្រស្រេចជាប្អូន"។

**គ.កាមរូបារម្មណ៍**

"ទុំថើបបីបមថ្នមប្រឡែង ទាំងពីរតតក្រែងរួមមេត្រី

នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្តី ស្រស់ស្រីស្រួលស្រើបដោយតណ្ហា"។

**ឃ.វេទនារូបារម្មណ៍**

"ទុក្ខប្អូនទៀតហើយទុំអឺយអ្នក នៅលើដំណាក់ក៏ភ្លេចខ្ញុំ

ឥឡូវប្អូនមកជ្រកដេកយំ ក្រាលក្រំដំបៅក្តៅឱរា"។

**៦.<u>កត្តាទី៦</u>:រឿងទុំទាវជាស្នាដៃអក្សរសិល្ប៍ដែលមានវិធីតែងនិពន្ធប្រកបដោយសិល្បៈខ្ពស់**

រឿងទុំទាវ ជាស្នាដៃឯករបស់ជាតិខ្មែរ ដោយសាររឿងនេះបានបង្ហាញឱ្យឃើញពីសិល្ប៍វិធីតែងនិពន្ធមានកម្រិតខ្ពស់។ សិល្បៈខ្ពស់នៃវិធីតែងនិពន្ធទាំងនោះរួមមានៈ

**ក.ប្រភេទអត្ថបទ** : រឿងទុំទាវជាស្នាដៃដែលសរសេរជាពាក្យកាព្យ បទពាក្យ៧ដ៏ពីរោះក្បោះក្បាយ រណ្តំណែងណង ត្រឹមត្រូវតាមក្បួនខ្នាត អាចទាក់ទាញប្រជាពលរដ្ឋយើងឱ្យសប្បាយរីករាយ និងចូលចិត្តនិយមរាប់អាន ធ្វើឱ្យអ្នកអាន អ្នកស្តាប់ យល់ដឹង និងចងចាំសាច់រឿង ហើយមានអារម្មណ៍តាមដំណើររឿង។

**ខ.សាច់រឿង** : ដំណើររឿងមានភាពប្រទាក់ក្រឡាគ្នាតាំងពីដើមរហូតដល់ចប់ គឺបង្ហាញគ្រប់សកម្មភាពមនុស្ស គ្រប់ស្រទាប់វណ្ណៈ និងឆ្លុះបញ្ចាំងពីជីភាពរស់នៅរបស់មនុស្សលោកិយពិតៗឥតក្លែងបន្លំដូចជា ប្រពៃណីទំនៀមទម្លាប់ ការព្យាបាទសងសឹក ការច្រណែនឈ្នានីស ការកាប់សម្លាប់ ការរំលោភបំពាន ការប្រើកម្លាំងផ្ទាល់ខ្លួនឬអំណាច ការតស៊ូមតិ និងភក្តីភាពជាដើម។

**គ.ពាក្យសម្ដី** : ការប្រើពាក្យសម្ដីក្នុងរឿងនេះ អ្នកនិពន្ធបានប្រើត្រឹមត្រូវសមរម្យណាស់។ ពាក្យសាមញ្ញក៏ពិតជាសាមញ្ញ រាជស័ព្ទក៏ត្រឹមត្រូវ ពាក្យសម្រាប់ព្រះសង្ឃ ឬពាក្យពិសេសសម្រាប់ពិធីទំនៀមទម្លាប់ណាមួយ ក៏ត្រឹមត្រូវតាមការនិយាយរបស់ពិធីនោះពិតៗដែរ។ មិនតែប៉ុណ្ណោះ ពាក្យមួយម៉ាត់ៗសុទ្ធតែមានន័យគ្រប់គ្រាន់ហើយវែងឆ្ងាយទៀត។ ចំណែកសម្ដីសួរ សម្ដីឆ្លើយ ពាក្យថ្ងូរ ពាក្យលាន់មាត់ដោយរំភើបចិត្ត សុទ្ធសឹងមានសកម្មភាពមានចលនារស់រវើក នាំឱ្យអ្នកអានងាយយល់មិនធុញថប់។

**ឃ.ដំណើររឿងឬខណៈរឿង** : ដំណើររឿងត្រូវបានអ្នកនិពន្ធចែកជាបីខណៈធំៗ :

- ខណៈទី១ ទុំនិងទាវបានគ្នាជាប្ដីប្រពន្ធ : ចាប់ពីទុំនៅវត្តវិហារធំ រហូតដល់ទុំនិងទាវលួចលាក់ស្រលាញ់គ្នា។

- ខណៈទី២ ទុំនិងទាវបានទៅនៅឯវាំងលង្វែក : ចាប់ពីភាពល្បីរបស់ទុំឮដល់វាំងលង្វែក រហូតដល់ព្រះរាជាប្រទានពិធីរៀបមង្គលការ។

- ខណៈទី៣ មរណភាពរបស់ទុំទាវ : ចាប់ពីម្ដាយទាវក្លែងសំបុត្រ រហូតដល់ចុងបញ្ចប់នៃរឿងទុំទាវ។

**ង.ទំនាស់** :មានទំនាស់តិច ត្រឹមតែបីប៉ុណ្ណោះ។ ទំនាស់ទី១ គឺទំនាស់ស្នេហានិងកិត្តិយស ដែលគូទំនាស់មានទុំទាវ និងម្ដាយទាវ។ ទំនាស់ទី២ គឺទំនាស់ស្នេហា និងជីវិត ដែលគូទំនាស់មានទុំទាវនិងរបបសក្ដិភូមិ។ ទំនាស់ទី៣ គឺទំនាស់វិបត្តិអំណាចសក្ដិភូមិដែលគូទំនាស់មានសក្ដិភូមិនិងសក្ដិភូមិ ប៉ុន្តែអាចបកស្រាយនូវបាតុភូតនៃសង្គមទាំងមូលបានយ៉ាងល្អ។

ក្រៅពីនេះ រឿងទុំទាវក៏នៅបានប្រាប់ពីឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទនៃការតែងនិពន្ធយ៉ាងច្បាស់លាស់ផងដែរ(ភិក្ខុសោម ១៩១៥)។ ចំណែកតួអង្គវិញ ក៏អ្នកនិពន្ធប្រើចំនួនតិចល្មមត្រឹមតែ១២តួអង្គប៉ុណ្ណោះ ដូចជាទុំ ទាវ ម្ដាយទាវ អរជូន ម៉ឺនងួន ព្រះបាទរាមា ម្ដាយទុំ ភរិយាអរជូន នាងនោ ពេជ្រ ព្រះចៅអធិការ និងប្រជាជន តែបានធ្វើឱ្យដំណើររឿងប្រព្រឹត្តទៅយ៉ាងរលូន និងរស់រវើក។

**៧.<u>កត្តាទី៧</u>: រឿងទុំទាវជាស្នាដៃអក្សរសិល្ប៍ដែលបានផ្ដល់តម្លៃអប់រំជាសកលដល់មនុស្សទូទៅគ្រប់សម័យកាល**

រឿងទុំទាវបានផ្ដល់ជាគតិបណ្ឌិតដល់មនុស្សទូទៅរួមមាន៖

- ចំណេះវិជ្ជា ជាឫសគល់ពិតប្រាកដក្នុងការកសាងឧត្តមភាពរបស់មនុស្ស
- ដាស់តឿនដល់ឪពុកម្ដាយទាំងឡាយ ត្រូវបើកសិទ្ធិសេរីភាពដល់កូនក្នុងការជ្រើសរើសគូស្រករ
- ទ្រព្យសម្បត្តិនិងសម្ភារៈទំនើប មិនមែនជាសុភមង្គលពិតប្រាកដរបស់មនុស្សទេ
- ក្រើនរំឭកដល់កូន ត្រូវចេះស្ដាប់ឪពុកម្ដាយ គ្រូអាចារ្យ កុំលង់ខ្លួនក្នុងភ្លើងតណ្ហានាំឱ្យរងក្នុងក្ដីវិនាស
- ដាស់តឿនអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់កុំប្រើអំណាចផ្ដាច់ការលើរាស្ត្រ ត្រូវគិតគូសុខទុក្ខរាស្ត្រគ្រប់ពេលវេលា ត្រូវធ្វើជាគំរូដល់រាស្ត្រ ដើម្បីអភិវឌ្ឍសង្គម
- អប់រំមនុស្សត្រូវចេះដោះស្រាយបញ្ហាដោយសន្តិវិធី កុំយកកំហឹងទល់កំហាល់ ត្រូវឈ្លាសវៃ មិនត្រូវយកស្រី ស្រាជាត្រីមុខ នាំឱ្យវិនាសខ្លួន
- ជាពិសេស អប់រំឱ្យមើលឃើញពីតួនាទីនៃវត្តអារាមព្រះពុទ្ធសាសនា ចំពោះសង្គមខ្មែរ។ តាមរយៈនេះ យើងឃើញថា វត្តអារាមជាសារមន្ទីរនៃស្ថាបត្យកម្ម ជាកន្លែងបង្កើតស្នាដៃនិពន្ធ ជាកន្លែងអប់រំវិជ្ជាជីវៈ ជាកន្លែងអប់រំសីលធម៌ និងជាកន្លែងផ្សាយវប្បធម៌ប្រកបដោយសក្ដានុពល។

**៨.<u>កត្តាទី៨</u>:ខ្លឹមសារនៃរឿងទុំទាវបានឆ្លើយតបទៅនឹងការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព(ESD)**

ដំណើររឿងទុំទាវ បានរំលេចឱ្យឃើញពីបញ្ហានានាជាច្រើន ទាំងបញ្ហាសង្គម បញ្ហាបរិស្ថាន និងបញ្ហាសេដ្ឋកិច្ចដ៏សម្បូរបែបដែលបានឆ្លើយតបយ៉ាងចំគោលដៅ ទៅនឹងការអប់រំប្រកបដោយនិរន្តរភាពទាំង៥ចំណុចរបស់អង្គការUNESCO (Five pillars of ESD) ៖

ក.រៀនដើម្បីយល់ដឹង(Learning to know)

ខ.រៀនដើម្បីត្រៀមខ្លួន (Learning to be)

គ.រៀនរស់នៅជាមួយគ្នា (Learning to live together)

ឃ.រៀនដើម្បីជំនាញ (Learning to do)

ង.រៀនដើម្បីផ្លាស់ប្តូរខ្លួនឯងនិងសង្គម (Learning to transform oneself and society )

## សន្និដ្ឋាន

រឿងទុំទាវជាស្នាដៃដ៏ល្អបំផុតក្នុងខឿនវប្បធម៌ខ្មែរ។ រឿងនេះតំណាងឱ្យព្រលឹងជាតិខ្មែរ ព្រោះវាបានឆ្លុះបញ្ចាំងនូវតថភាពសង្គមខ្មែរនាសម័យលង្វែកគ្រប់ជ្រុងជ្រោយទាំងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ ជីវភាពរស់នៅ មុខរបរ ទស្សនៈរបស់ខ្មែរ។ ក្រៅពីនេះ តាមរយៈរឿងទុំទាវ ក៏បានបង្ហាញឱ្យឃើញពីសិល្បៈខ្ពស់ក្នុងការតែងនិពន្ធលេចធ្លោជាងស្នាដៃអក្សរសិល្ប៍នានា ទាំងសិល្បបារម្មណ៍ និងការប្រើប្រាស់ពាក្យពេចន៍។ ចំណែកខាង ឧត្តមគតិរឿងក៏បានផ្តល់ តម្លៃអប់រំជាទូទៅដល់មនុស្សគ្រប់ជំនាន់ឱ្យទទួលបាននូវកុសលនិងសច្ចៈតាមបែបមនុស្សលោកិយ។ ជាពិសេសខ្លឹមសារនៃរឿងបានឆ្លើយតបទៅនឹងការអប់រំជាសកលក្នុងសតវត្សទី២១យើងនេះ។ ដូច្នេះ ក្នុងនាមយើងជាកូនខ្មែរគ្រប់រូប យើងគប្បីសិក្សាស្នាដៃអក្សរសិល្ប៍នៃរឿងទុំទាវបន្ថែមទៀត ដើម្បីលើកកម្ពស់តម្លៃអក្សរសាស្ត្រ អក្សរសិល្ប៍ជាតិផង និងដើម្បីដកស្រង់បទពិសោធល្អៗតាមរយៈស្នាដៃនេះផង ប្រយោជន៍សម្រាប់ឱ្យបុគ្គលខ្លួនឯងទទួលបាននូវកិត្តិយសនិងសេចក្តីថ្លៃថ្នូរ គ្រួសារមានសុភមង្គលនិងមានភាពកក់ក្តៅ ហើយសង្គមជាតិទាំងមូលមានការរីកចម្រើនលើគ្រប់វិស័យ។